# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះបង្ហាញពី សូចនាករសេដ្ឋកិច្ចនៃសេដ្ឋកិច្ចពិភពលោកធំៗមួយចំនួន និងបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ក្នុងត្រីមាសទី៤ ឆ្នាំ២០២០។ នៅពេលសរសេរទិន្នន័យស្ដីពីកំណើន ផលិតផលក្នុងស្រុកសរុប ពិតនៅកម្ពុជា មិនទាន់មានទេ។

## កំណើនផលិតផលក្នុងស្រុកសរុប (ផសស) ពិត

គេអាចមើលឃើញភ្លាម GDP ពិតនៅក្នុងប្រទេសដែលជ្រើសរើសភាគច្រើន បានរើបឡើងវិញពីត្រីមាសមុនលើកលែងតែករណីម៉ាឡេស៊ី កូរ៉េខាងត្បូង និង Euro-12។ ទោះមានការរើបឡើងវិញពីត្រីមាសមុនក៏ដោយ ក៏កំណើនផសស ពិតរបស់ប្រទេសទាំងនេះនៅតែទាបជាងត្រីមាសទី៤ ឆ្នាំ២០១៩ លើកលែងតែប្រទេសចិន និងតៃវ៉ាន់ ដែលសម្រេចបានអត្រាកំណើនប្រចាំឆ្នាំ ខ្ពស់ជាង ០,៥% និង ១,៦% ក្នុងអំឡុងពេលជំងឺរាតត្បាតនេះ។

ចាប់ផ្ដើមជាមួយប្រទេសអាស៊ានជ្រើសរើស ម៉ាឡេស៊ី គឺជាប្រទេសតែមួយគត់ ដែលបន្តមានអត្រាធ្លាក់ចុះខ្ពស់ជាងគេគឺ ៣,៤% ត្រូវជា ០,៧% ខ្ពស់ជាងត្រីមាសមុន និង ៧,០% ខ្ពស់ជាងនៅត្រីមាសដូចគ្នាកាលពីឆ្នាំមុន។ វៀតណាម គឺជាប្រទេសតែមួយគត់ដែលមិនធ្លាប់ជួបប្រទះកំណើនអវិជ្ជមាន បើទោះបីជាអត្រាកំណើនទាបជាង កាលពីត្រីមាសទី៣ ក្នុងឆ្នាំ២០២០ ដែលមានកំណើនក្នុងកម្រិតខ្ពស់បំផុតដល់ ៧,៣%។ អត្រាកំណើនទាបបំផុតរបស់វៀតណាមធ្លាក់ដល់ ០,៤% នៅត្រីមាសទី២ ឆ្នាំ២០២០ ហើយរើបឡើងវិញយ៉ាងឆាប់រហ័ស នៅត្រីមាសបន្ទាប់ដល់ ២,៣% នៅត្រីមាសទី៣ និង ៤,៥% នៅត្រីមាសទី៤ ឆ្នាំ២០២០។ អត្រាកំណើនអវិជ្ជមាននៅឥណ្ឌូនេស៊ី មាននិន្នាការថយចុះ ដោយចាប់ផ្ដើមខិតជិតដល់អត្រាកំណើនវិជ្ជមានម្ដងទៀត។ កំណើនអវិជ្ជមាននៅប្រទេសនេះ មានរហូតដល់ -៥,៣% នៅក្នុងត្រីមាសទី២ បន្ទាប់មករើបឡើងវិញដល់ -៣,៥% នៅក្នុងត្រីមាសទី៣ និងដល់ -២,២% នៅក្នុងត្រីមាសនេះ។ នេះគឺជាអត្រាកំណើនអវិជ្ជមានទាបបំផុត បើប្រៀបធៀបជាមួយនឹងប្រទេសថៃ (ដែលមានខ្ពស់បំផុតនៅ -៤,២%) ម៉ាឡេស៊ី (-៣,៤%) និងសិង្ហបុរី (-២,៤%)។ គួរកត់សម្គាល់ផងដែរថា ទោះបីជាមានការធ្លាក់ចុះក៏ដោយ សិង្ហបុរីសម្រេចបានកំណើនគួរឱ្យកត់សម្គាល់ ៣,៤ ឯកតាភាគរយ ពីត្រីមាសមុន និង ១០,៨ ឯកតាភាគរយ បើប្រៀបធៀបនឹងតួលេខធ្លាក់ចុះដ៏អាក្រក់បំផុតរបស់ខ្លួន (-១៣,២%) ក្នុងត្រីមាសទី២ ឆ្នាំ២០២០។ ប្រទេសថៃក៏ស្ថិតនៅលើផ្លូវរើបឡើងវិញ ដូចសិង្ហបុរីដែរ។

ក្នុងចំណោមបណ្ដាប្រទេសអាស៊ី ដែលជ្រើសរើសផ្សេងទៀត ប្រទេសចិនបានជួបប្រទះអត្រារើបឡើងវិញលឿនបំផុត បើប្រៀបធៀបជាមួយនឹងប្រទេសដទៃទៀតនៅក្នុងក្រុមនេះ និងប្រទេសដែលបានជ្រើសរើសទាំងអស់នៅក្នុងក្រុមផ្សេងទៀត ហើយឈានដល់អត្រាកំណើនខ្ពស់បំផុតរបស់ខ្លួននៅក្នុងត្រីមាសនេះបើប្រៀបធៀបទៅនឹងត្រីមាសមុនៗទាំងអស់ ដោយរាប់ចាប់ពីត្រីមាសទី១ ឆ្នាំ២០១៩។ អត្រាកំណើនរបស់ប្រទេសចិននៅក្នុងត្រីមាសទី៤ ឆ្នាំ២០២០ នេះ គឺ ៦,៥% ដែលត្រូវជា ១,៦ ឯកតាភាគរយខ្ពស់ជាងត្រីមាសមុន និងខ្ពស់ជាង ០,៥% នៅក្នុងត្រីមាសដូចគ្នាកាលពីឆ្នាំមុន។ តៃវ៉ាន់មានអត្រាកំណើនខ្ពស់បំផុតទី២ (៤,៩%) បន្ទាប់ពីប្រទេសចិន បើធៀបជាមួយក្រុមប្រទេសជ្រើសរើសទាំងអស់នៅក្នុងត្រីមាសនេះ ដែលបង្ហាញពីការរើបឡើងវិញយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់អំពីការធ្លាក់ចុះ ០,៦% នៅត្រីមាសទី២ ឆ្នាំ២០២០។ ទីក្រុងហុងកុង ស្ថិតក្នុងកំណើនអវិជ្ជមានដល់ -៣,០% បើទោះជាមានការស្ទុះឡើងបាន ០,៥ ឯកតាភាគរយពីត្រីមាសមុនក៏ដោយ។ ប្រទេសកូរ៉េខាងត្បូងមាននិន្នាការអត្រាកំណើនផ្ទុយពីគេ ដោយប្រទេសនេះ ជួបប្រទះអត្រាកំណើនអវិជ្ជមាន ០,២ ឯកតាភាគរយ ខ្ពស់ជាងត្រីមាសមុន ដល់ ១,៣% នៅត្រីមាសនេះ ដែលទាបជាងកំណើន ៤,៧ ឯកតាភាគរយ នៅក្នុងត្រីមាសដូចគ្នាកាលពីឆ្នាំមុន។

ប្រទេសឧស្សាហកម្មដែលជ្រើសរើសទាំងបី នៅតែជួបប្រទះនឹងរយៈពេលនៃកំណើនអវិជ្ជមាននៅក្នុងត្រីមាសនេះ ដោយសារការរីករាលដាលជំងឺរាតត្បាតសកល។ ប្រទេសជប៉ុនកំពុងស្ទុះងើបឡើងវិញយ៉ាងឆាប់រហ័ស ក្នុងចំណោមប្រទេសទាំងបី ដោយបង្ហាញពីនិន្នាការកំណើនវិជ្ជមាន បើទោះបីជានៅមានកំណើនអវិជ្ជមាន ១,៤% ក្នុងត្រីមាសនេះក៏ដោយ។ ទោះជាយ៉ាងណាវាជាការកើនឡើង ៤,៣% ពីត្រីមាសមុន ដែលត្រូវជា ០,៧ ឯកតាភាគរយ ដើម្បីស្មើនឹងកំណើនអវិជ្ជមានទាបបំផុតរបស់ខ្លួននៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៩។ បើប្រៀបធៀបទៅនឹងការធ្លាក់ចុះដ៏អាក្រក់បំផុតរបស់ខ្លួន (-១៤,៧%) នៅក្នុងត្រីមាសទី២ ឆ្នាំ២០២០ ប្រទេសអឺរ៉ុប-១២ ក៏បានងើបឡើងវិញយ៉ាងឆាប់រហ័សដល់ -៥,១% នៅក្នុងត្រីមាសនេះ ទោះបីជាអត្រាកំណើនអវិជ្ជមាននេះ នៅ ៨,៥% ខ្ពស់ជាងត្រីមាសមុនក៏ដោយ។ មិនដូចប្រទេសអឺរ៉ុប-១២ អាមេរិកបានបន្តការធ្លាក់ចុះបន្តិចម្ដងៗ ពីកំណើនអវិជ្ជមាន ពី -៩,៥% នៅត្រីមាសទី២ ឆ្នាំ២០២០ មកនៅត្រឹម -២,៨% នៅត្រីមាសទី៣ និងដល់ -២,៥% នៅត្រីមាសនេះ។

## អត្រាអតិផរណា

នៅត្រីមាសទី៤ ឆ្នាំ២០២០ ប្រទេសចំនួន ៦ ក្នុងចំណោមប្រទេសទាំង១៣ជ្រើសរើស ជួបប្រទះបញ្ហាបរិត្តផរណា៖ ម៉ាឡេស៊ី (-១,៥%) សិង្ហបុរី (-០,១%) ថៃ (-០,៤%) ហុងកុង (-០,៣%) អឺរ៉ូ-១២ (-០,៣%) និងជប៉ុន (-០,៩%)។ ប្រទេសកម្ពុជាមានអត្រាអតិផរណាខ្ពស់បំផុត (៣,៤%) បន្ទាប់មកប្រទេសឥណ្ឌូនេស៊ី (១,៦%) វៀតណាម (១,៤%) សហរដ្ឋអាមេរិក (០,៨%) កូរ៉េខាងត្បូង (០,៣%) និងចិន (០,១%)។

បើធៀបនឹងត្រីមាសមុន នៅក្នុងប្រទេសអាស៊ីដែលជ្រើសរើសអត្រាអតិផរណានៅកម្ពុជា កើនឡើង ០,៦ ឯកតាភាគរយ និងនៅឥណ្ឌូនេស៊ី ០,២ ឯកតាភាគរយ ចំណែកវៀតណាម ធ្លាក់ចុះ ១,៨ ឯកតាភាគរយ។ ក្នុងចំណោមប្រទេសទាំងបីនៅក្នុងក្រុមប្រទេសនេះ ជួបប្រទះបញ្ហាបរិត្តផរណា មានតែម៉ាឡេស៊ីទេដែល

---

អត្ថបទនេះ រៀបរៀងដោយលោក រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ នៅវិទ្យាស្ថាន CDRI។

មានអត្រាបរិត្តផរណាខ្ពស់ជាងនេះ (-១,៥%) កើនបាន ០,១ ពីត្រីមាសមុន ខណៈអត្រាបរិត្តផរណានៅសិង្ហបុរី ធ្លាក់ចុះ ០,២% និងនៅថៃ ០,៤%។

មានតែមួយគត់ ក្នុងចំណោមដែនដីអាស៊ីជ្រើសរើសផ្សេងទៀត ដែលជួបប្រទះបញ្ហាបរិត្តផរណានៅត្រីមាសនេះគឺ ទីក្រុងហុងកុង ដែលអត្រាបរិត្តផរណាថយចុះ ០,៦% បើធៀបនឹងត្រីមាសមុន។ ប្រទេសចិនមាននិន្នាការអត្រាអតិផរណាធ្លាក់ចុះពីកម្រិតកំពូល ៤,៤% នៅត្រីមាសទី៤ ឆ្នាំ២០១៩ មកត្រឹម ០,១% នៅត្រីមាសនេះ។ អត្រាអតិផរណានៅកូរ៉េខាងត្បូងមាន ០,៣% នៅត្រីមាសនេះ ដែលទាបជាង ០,៤ ឯកតាភាគរយ កាលពីត្រីមាសមុន ហើយតៃវ៉ាន់មានអត្រាអតិផរណា ០% កើនឡើង ០,៥% ពីអត្រាបរិត្តផរណា -០,៥% នៅត្រីមាសមុន។

ក្នុងចំណោមប្រទេសឧស្សាហកម្មជ្រើសរើស មានតែសហរដ្ឋអាមេរិកទេ ដែលមិនជួបប្រទះបញ្ហាបរិត្តផរណា ក្នុងកំឡុងពេលទិន្នន័យបង្ហាញនៅក្នុងរបាយការណ៍នេះ។ អតិផរណានៅសហរដ្ឋអាមេរិកមាន ០,៨% នៅក្នុងត្រីមាសនេះ ដែលជាការធ្លាក់ចុះ ០,៤ ឯកតាភាគរយ បើធៀបនឹងត្រីមាសមុន និងទាបជាងត្រីមាសទី៤ ឆ្នាំ២០១៩ ចំនួន ១,៣។ អត្រាបរិត្តផរណា ០,៣% នៅក្នុងប្រទេសអឺរ៉ុប-១២ នៅត្រីមាសនេះ បង្ហាញពីការធ្លាក់ចុះ ០,៣% ពីអត្រាអតិផរណា ០% នៅក្នុងត្រីមាសមុន។ អត្រាអតិផរណា ០,៩% នៅជប៉ុនក្នុងត្រីមាសនេះ បង្ហាញពីការធ្លាក់ចុះ ១,១ឯកតាភាគរយ ពីអត្រាអតិផរណា ០,២ នៅក្នុងត្រីមាសមុន។

## អត្រាប្តូរប្រាក់

លើកលែងតែប្រាក់ដុល្លារហុងកុងទេ បើធៀបនឹងត្រីមាសមុន រូបិយប័ណ្ណប្រទេសជ្រើសរើសទាំងអស់ បានឡើងថ្លៃ ធៀបនឹងដុល្លារអាមេរិក៖ ប្រាក់រៀល (០,៦%) ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ី (២,២%) រីងហ្គីតម៉ាឡេស៊ី (២,៤%) ប្រាក់ដុល្លារសិង្ហបុរី (៧,១%) ប្រាក់បាតថៃ (២,២%) ប្រាក់ដុងវៀតណាម (០,១%) ប្រាក់យ័នចិន (៤,៣%) ប្រាក់វ៉ុនកូរ៉េខាងត្បូង (៥,៩%) ប្រាក់ដុល្លារតៃវ៉ាន់ (២,៧%) ប្រាក់អឺរ៉ូ (១១,១%) និងប្រាក់យ៉េនជប៉ុន (១,៧%)%)។ អត្រាប្តូរប្រាក់ដុល្លារហុងកុង ប្រៀបធៀបនឹងដុល្លារអាមេរិក នៅតែមានស្ថិរភាពក្នុងអត្រា ៧,៨ ដុល្លារហុងកុង ដល់ ១ ដុល្លារអាមេរិក ក្នុងកំឡុងពេលទិន្នន័យមាននៅក្នុងរបាយការណ៍នេះ។

## ថ្លៃទំនិញលើទីផ្សារពិភពលោក

ធៀបនឹងត្រីមាសមុន តម្លៃស្រូវ និងប្រេងសាំង បានធ្លាក់ចុះ ខណៈដែលតម្លៃពោត ប្រេងដូង កៅស៊ូ សណ្តែកសៀង ប្រេងឆៅ និងប្រេងម៉ាស៊ូត បានកើនឡើង។ តម្លៃពោតបានកើនឡើង ២៣,១% ដល់ ១៩២,០ ដុល្លារក្នុងមួយតោន ប្រេងដូង ២២,៣% ដល់ ៩១៧,៨ ដុល្លារក្នុងមួយតោន កៅស៊ូកើនឡើង ២១,៩% ដល់ ១៦០៥,០ ដុល្លារក្នុងមួយតោន សណ្តែកសៀង ២៧,៩% ដល់ ៤៨៥,៥ ដុល្លារក្នុងមួយតោន ប្រេងឆៅ ៣,៣% ដល់ ៤៣,៨ ដុល្លារក្នុងមួយធុង និងម៉ាស៊ូត ៧,៥% ដល់ ៣២,៨ សេនក្នុងមួយលីត្រ។ តម្លៃអង្ករបានធ្លាក់ចុះ ៣,៩% មកត្រឹម ៤៩៣,៣ ដុល្លារក្នុងមួយតោន និងប្រេងសាំង ០,៦% មកត្រឹម ៣១,៤ សេនដុល្លារក្នុងមួយលីត្រ។ ធៀបនឹងត្រីមាសដូចគ្នាកាលពីឆ្នាំមុន តម្លៃប្រេងឆៅ ប្រេងសាំង និងម៉ាស៊ូត បានធ្លាក់ចុះ ចំណែកឯតម្លៃទំនិញកសិកម្មជ្រើសរើសទាំងអស់ បានកើនឡើង។ តម្លៃប្រេងឆៅ បានធ្លាក់ចុះ ២៧,៤% ប្រេងសាំង ២៧,៥% និងប្រេងម៉ាស៊ូត ៣៣,៦%។ តម្លៃពោតពីមួយឆ្នាំទៅមួយឆ្នាំ បានកើនឡើង ១៥,១% ប្រេងដូង ៣៤,៩% កៅស៊ូ កើនឡើង ១៣,៨% អង្ករកើនឡើង ១១,៤% និងសណ្តែកសៀង ៣៩,៨%។

តារាង១៖ កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៥-២០២០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.0 | 7.0 | 7.0 | 7.5 | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 4.8 | 5.0 | 5.1 | 5.2 | 5.1 | 5.0 | 5.0 | 5.0 | 3.0 | -5.3 | -3.5 | -2.2 |
| ម៉ាឡេស៊ី | 4.9 | 4.3 | 5.9 | 4.8 | 4.5 | 4.9 | 4.4 | 3.6 | 0.7 | -17.1 | -2.7 | -3.4 |
| សិង្ហបុរី | 2.0 | 2.0 | 3.8 | 3.2 | 1.3 | 0.1 | 0.5 | 0.8 | -2.2 | -13.2 | -5.8 | -2.4 |
| ថៃ | 2.8 | 3.2 | 3.8 | 4.1 | 2.8 | 2.3 | 2.4 | 1.6 | -1.8 | -12.2 | -6.4 | -4.2 |
| វៀតណាម | 6.6 | 6.1 | 6.6 | 7.2 | 6.8 | 6.7 | 7.3 | 7.0 | 3.8 | 0.4 | 2.3 | 4.5 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 7.0 | 6.7 | 6.9 | 6.6 | 6.4 | 6.2 | 6.0 | 6.0 | -6.8 | 3.2 | 4.9 | 6.5 |
| ហុងកុង | 2.3 | 1.7 | 2.8 | 3.1 | 0.6 | 0.5 | 2.9 | -2.9 | -8.9 | -9.0 | -3.5 | -3.0 |
| កូរ៉េខាងត្បូង | 2.6 | 2.6 | 3.0 | 3.0 | 1.8 | 2.1 | 2.0 | 3.4 | 1.3 | -3.0 | -1.1 | -1.3 |
| តៃវ៉ាន់ | 0.6 | 1.2 | 2.8 | 2.6 | 1.7 | 2.4 | 3.0 | 3.3 | 1.5 | -0.6 | 3.9 | 4.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ុ-១២ | 1.3 | 1.6 | 2.3 | 1.9 | 1.2 | 1.1 | 1.2 | 1.0 | -3.3 | -14.7 | -4.3 | -5.1 |
| ជប៉ុន | 0.3 | 0.9 | 1.8 | 0.6 | 0.9 | 1.2 | 1.7 | -0.7 | -2.0 | -9.9 | -5.7 | -1.4 |
| សហរដ្ឋអាមេរិក | 2.3 | 1.6 | 2.3 | 3.0 | 3.2 | 2.3 | 2.1 | 2.3 | 0.3 | -9.5 | -2.8 | -2.5 |

Sources: International Monetary Fund; Economist; countries' statistics offices

តារាង២៖ អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៥-២០២០ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 1.2 | 3.0 | 2.9 | 2.5 | 1.9 | 1.8 | 2.0 | 2.1 | 3.0 | 2.5 | 2.8 | 3.4 |
| ឥណ្ឌូនេស៊ី | 6.4 | 3.5 | 3.8 | 3.2 | 2.6 | 3.1 | 3.4 | 2.9 | 2.9 | 2.3 | 1.4 | 1.6 |
| ម៉ាឡេស៊ី | 2.1 | 2.1 | 3.9 | 1.0 | -0.3 | 0.6 | 1.3 | 1.0 | 0.9 | -2.6 | -1.4 | -1.5 |
| សិង្ហបុរី | -0.5 | -0.8 | 0.6 | 0.4 | 0.5 | 0.8 | 0.5 | 0.6 | 0.4 | -0.7 | -0.3 | -0.1 |
| ថៃ | -0.9 | 0.2 | 0.7 | 1.1 | 0.7 | 1.1 | 0.6 | 0.4 | 0.4 | -2.7 | -0.8 | -0.4 |
| វៀតណាម | 0.6 | 2.7 | 3.4 | 3.6 | 2.6 | 2.7 | 2.2 | 3.7 | 5.6 | 2.8 | 3.2 | 1.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 1.4 | 2.0 | 1.6 | 2.1 | 1.8 | 2.6 | 2.9 | 4.3 | 4.4 | 2.7 | 2.3 | 0.1 |
| ហុងកុង | 3.1 | 2.5 | 1.7 | 2.4 | 2.2 | 2.7 | 3.4 | 3.0 | 2.0 | 1.3 | -0.9 | -0.3 |
| កូរ៉េខាងត្បូង | 0.7 | 0.8 | 2.0 | 1.4 | 0.6 | 0.7 | 0.1 | 0.3 | 1.2 | -0.1 | 0.7 | 0.3 |
| តៃវ៉ាន់ | 0.6 | 1.4 | 0.6 | 1.4 | 0.3 | 0.8 | 0.4 | 0.7 | 0.6 | -1.0 | -0.5 | 0.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.0 | 0.3 | 1.5 | 1.8 | 1.4 | 1.4 | 1.0 | 1.0 | 1.1 | 0.3 | 0.0 | -0.3 |
| ជប៉ុន | 0.9 | -0.1 | 0.6 | 1.0 | 0.3 | 0.7 | 0.3 | 0.5 | 0.5 | 0.1 | 0.2 | -0.9 |
| សហរដ្ឋអាមេរិក | 0.0 | 1.2 | 2.1 | 2.5 | 1.7 | 1.8 | 1.7 | 2.1 | 2.1 | 0.3 | 1.2 | 0.8 |

Sources: International Monetary Fund; Economist; National Institute of Statistics

តារាង៣៖ អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៥-២០២០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4060.4 | 4053.6 | 4047.0 | 4045.0 | 4006.6 | 4052.1 | 4086.8 | 4063.7 | 4064.1 | 4101.4 | 4105.7 | 4079.5 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 13394.8 | 13338.3 | 13379.8 | 14227.6 | 14127.8 | 14246.8 | 14117.6 | 14060.5 | 14220.3 | 14944.2 | 14690.0 | 14366.0 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.9 | 4.1 | 4.3 | 4.0 | 4.1 | 4.1 | 4.2 | 4.2 | 4.2 | 4.3 | 4.2 | 4.1 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.4 | 1.4 | 1.4 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.3 |
| ថៃ (បាត) | 34.2 | 35.3 | 33.9 | 32.3 | 31.6 | 31.6 | 30.7 | 30.3 | 31.2 | 32.0 | 31.3 | 30.6 |
| វៀតណាម (ដុង) | 21917.7 | 22507.5 | 22645.9 | 22663.3 | 22902.9 | 23255.5 | 23258.3 | 23217.3 | 23351.0 | 23244.6 | 23195.8 | 23174.2 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ័ន) | 6.3 | 6.6 | 6.8 | 6.6 | 6.7 | 6.8 | 7.0 | 7.0 | 7.0 | 7.1 | 6.9 | 6.6 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1131.9 | 1161.0 | 1130.5 | 1099.9 | 1125.0 | 1165.4 | 1193.4 | 1174.7 | 1191.5 | 1219.8 | 1188.5 | 1118.8 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់) | 31.8 | 32.3 | 30.4 | 30.1 | 30.8 | 31.1 | 31.2 | 30.5 | 30.1 | 29.9 | 29.3 | 28.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.9 | 0.9 | 0.9 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.8 |
| ជប៉ុន (យ៉េន) | 121.0 | 108.8 | 112.1 | 110.4 | 110.1 | 109.9 | 107.3 | 108.7 | 109.0 | 107.6 | 106.2 | 104.4 |

Sources: International Monetary Fund; Economist; National Bank of Cambodia

តារាង៤៖ ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១៥-២០២០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ពោត (US No.2) - USA (ដុល្លារ/តោន) | 169.8 | 159.2 | 154.5 | 164.4 | 167.5 | 175.9 | 170.1 | 166.8 | 167.6 | 146.3 | 156.0 | 192.0 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (ដុល្លារ/តោន) | 622.7 | 643.6 | 714.7 | 638.7 | 586.9 | 568.1 | 570.1 | 680.2 | 724.7 | 614.0 | 750.2 | 917.8 |
| កៅស៊ូ SMR 5 (ដុល្លារ/តោន) | 1392.7 | 1416.1 | 1688.3 | 1401.4 | 1436.6 | 1549.5 | 1389.7 | 1410.1 | 1374.4 | 1144.4 | 1316.5 | 1605.0 |
| អង្ករ (Thai 100% B) - បាងកក (ដុល្លារ/តោន) | 395.5 | 406.7 | 452.3 | 444.2 | 426.7 | 430.0 | 439.7 | 442.7 | 481.3 | 547.5 | 513.3 | 493.3 |
| សណ្តែកសៀង (US No.1) - USA (ដុល្លារ/តោន) | 390.4 | 405.7 | 400.6 | 405.4 | 353.3 | 347.8 | 339.7 | 347.3 | 360.7 | 349.4 | 379.5 | 485.5 |
| ប្រេងឆៅ - OPEC spot (ដុល្លារ/ធុង) | 49.6 | 40.7 | 52.6 | 69.5 | 60.5 | 65.1 | 59.7 | 60.3 | 49.1 | 30.3 | 42.4 | 43.8 |
| សាំង - US Gulf Coast (សេនដុល្លារ/លីត្រ) | 41.0 | 35.2 | 42.4 | 49.6 | 40.9 | 49.4 | 46.0 | 43.3 | 34.2 | 21.8 | 31.6 | 31.4 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេនដុល្លារ/លីត្រ) | 41.7 | 34.8 | 42.9 | 53.8 | 49.5 | 51.1 | 48.9 | 49.4 | 39.2 | 24.0 | 30.5 | 32.8 |

Sources: Food and Agriculture Organisation; US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៤ ឆ្នាំ២០២០ ការអនុម័តវិនិយោគជាទ្រព្យសកម្មជាប់លាប់សរុប ធ្លាក់ចុះ ៣០,៣% ធៀបនឹងឆ្នាំចាស់ ដែលស្មើនឹង ១៦៦៣,៨លានដុល្លារអាមេរិកដែលបង្ហាញពីការថយចុះ ៥៥,០% ធៀបនឹងត្រីមាសមុន។ ការអនុម័តសូន្យ ត្រូវបានកត់សម្គាល់លើវិស័យពីរនៅត្រីមាសទី៤ ឆ្នាំ២០២០ គឺវិស័យកសិកម្ម សណ្ឋាគារ និងទេសចរណ៍។ ការអនុម័តលើ វិស័យកសិកម្មនៅត្រីមាសមុន មានចំនួន ៣១,៧លានដុល្លារ ហើយសម្រាប់សណ្ឋាគារ និងទេសចរណ៍វិញ មានដល់ ៣,៥១៥.១លានដុល្លារ។ ធៀបនឹងឆ្នាំចាស់ មានតែការអនុម័តសម្រាប់ឧស្សាហកម្មប៉ុណ្ណោះ បានកើនឡើង (៧៩,៨%) ប៉ុន្តែធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០ នេះបង្ហាញពីការធ្លាក់ចុះ ១៤,៨%។ អនុម័តលើវាយនភណ្ឌកាត់ដេរបានថយចុះ ២៣,៩% ធៀបនឹងឆ្នាំចាស់ ប៉ុន្តែមាន ៨៩,៩% ខ្ពស់ជាងកាលពីត្រីមាសមុន។ ការអនុម័តលើវិស័យសេវាកម្ម បានធ្លាក់ចុះ ៩៩,៣% ធៀបនឹងត្រីមាសដូចគ្នាកាលពីឆ្នាំមុន ហើយត្រូវជា ៩៩,៤% ទាបជាងត្រីមាសមុន។

ការមកដល់របស់ភ្ញៀវអន្តរជាតិធ្លាក់ចុះ ៩៦,៧% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩ មកត្រឹម ៥៨,៥០០នាក់ គឺធ្លាក់ចុះ ៩,៩% ធៀបនឹងត្រីមាសមុន។ នៅត្រីមាសទី៤ ឆ្នាំ២០២០ ការមកដល់របស់ភ្ញៀវទេសចរចិន មានភាគរយច្រើនជាងគេ (៤៥,៨%) ធៀបនឹងចំនួនភ្ញៀវទេសចរអន្តរជាតិសរុប បន្ទាប់មកថៃ (៣៦,៦%) កូរ៉េខាងត្បូង (២,៦%) វៀតណាម (២,៤%) សហរដ្ឋអាមេរិក (២,២%) ជប៉ុន (១,០%) បារាំង (១,០%) ម៉ាឡេស៊ី (០,៧%) និងចក្រភពអង់គ្លេស (០,៣%)។ ធៀបនឹងឆ្នាំចាស់ ការមកដល់នៃប្រទេសទាំងនេះបានធ្លាក់ចុះ ហើយមានតែការមកដល់ពីប្រទេសចំនួនពីរប៉ុណ្ណោះ គឺម៉ាឡេស៊ី និងវៀតណាម បានកើនឡើង បើប្រៀបធៀបនឹងត្រីមាសមុនគឺ ៣៣,៣% និង ២៧,៣% រៀងៗខ្លួន។ គួរកត់សម្គាល់ថា ការមកដល់អន្តរជាតិពីប្រទេសចំនួន ៩ ដែលរាយការណ៍ សរុបមាន ៩២,៦% មានន័យថា ៧,៤% បានមកកម្ពុជា ពីប្រទេសដទៃទៀតដែលមិនបានបញ្ជាក់នៅក្នុងរបាយការណ៍នេះ។

ក្នុងកំឡុងពេលមានជំងឺរាតត្បាតសកល កម្ពុជានាំចេញសរុបកើនឡើង ១២,៧% ធៀបនឹងឆ្នាំចាស់ ដល់ ៣.៩៧០,៩លានដុល្លារ ប៉ុន្តែតួលេខនេះតំណាងឱ្យការធ្លាក់ចុះ ២៨,៦% ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០។ ការនាំចេញកើនឡើងពីមួយឆ្នាំចាស់នេះ បានជំរុញជាចម្បង ដោយសារការមានកំណើនក្នុងការនាំចេញសម្លៀកបំពាក់(១,៩%)គ្រឿងអេឡិចត្រូនិក(៩៤,៨%) គ្រឿងបង្គុំរថយន្ត (៧៧,២%) កសិកម្ម (៥២,៨%) និងទំនិញដែលមិនបញ្ជាក់ (ត្រឹម ២១,៣)%)។ ក្នុងចំណោមប្រទេសនាំចូលសម្លៀកបំពាក់ធំៗចំនួន ៥ របស់កម្ពុជា ការនាំចេញបានកើនឡើងធៀបនឹងឆ្នាំចាស់ទៅកាន់ទិសដៅចំនួនពីរ គឺសហរដ្ឋអាមេរិក (១៥,១%) និងអាស៊ាន (០,៨%) ខណៈដែលមានការធ្លាក់ចុះនៅទិសដៅផ្សេងទៀត គឺចក្រភពអង់គ្លេស (១៥,៨%) ជប៉ុន (៧,២%) និងសហភាពអឺរ៉ុប (១,៨%)។ ការនាំចេញសម្លៀកបំពាក់ ទៅប្រទេសផ្សេងទៀត ធ្លាក់ចុះ (៣,៨%)។ ធៀបនឹងត្រីមាសមុន ការនាំចេញសម្លៀកបំពាក់ទៅអាស៊ាន បានកើនឡើង (៩,៦%) និងទៅសហភាពអឺរ៉ុប (៦,៣%) ចំណែកឯការនាំចេញទៅអាមេរិក បានធ្លាក់ចុះ (៦,០%) ជប៉ុន (៤,៨%) ចក្រភពអង់គ្លេស (២៤,៥%) និងប្រទេសផ្សេងទៀត (៨,៩%)។

ទោះបីមានជំងឺរាតត្បាត ការនាំចេញក្នុងប្រភេទអេឡិចត្រូនិក គ្រឿងបង្គុំរថយន្ត និងកសិកម្ម បានកើនឡើង ធៀបគ្នារវាងត្រីមាសទី៤ ឆ្នាំ២០២០ និងទាំងត្រីមាសដូចគ្នាឆ្នាំមុន និងត្រីមាសមុន។ ការនាំចេញគ្រឿងអេឡិចត្រូនិក ៩៤,៨% ខ្ពស់ជាងការនាំចេញឆ្នាំមុនក្នុងត្រីមាសដូចគ្នា និង ២៣,៧% ធៀបនឹងត្រីមាសមុន។ ការនាំចេញក្នុងប្រភេទគ្រឿងបង្គុំរថយន្ត កើនឡើង ៧៧,២% ពីឆ្នាំចាស់ ដែលមាន ២០,៦% ខ្ពស់ជាងត្រីមាសមុន។ ការនាំចេញក្នុងវិស័យកសិកម្ម កើនឡើង ៥២,៨% ពីឆ្នាំមុន និង ៥៨,៧% ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០។ ធៀបជាមួយពេលនេះពីឆ្នាំមុន ការមានកំណើនការនាំចេញកសិកម្ម គឺដោយសារតែមានកំណើនការនាំចេញកៅស៊ូ (៦២,៩%) ឈើ (១៧៥,៤%) អង្ករ (១,៧%) និងផលិតផលកសិកម្មផ្សេងទៀត (៧៥,៨%)។ ធៀបនឹងត្រីមាសមុន ការនាំចេញកៅស៊ូ កើនឡើង ៤៣,៧% ឈើ ៥២,១% អង្ករ ១២៧,៨% និងផលិតផលកសិកម្មផ្សេងៗ ៣,៧%។ គួរកត់សម្គាល់ថា ការនាំចេញត្រី នៅថេរត្រឹម ០,១លានដុល្លារអាមេរិក ចាប់តាំងពីត្រីមាសទី១ ឆ្នាំ២០១៩។

ការនាំចូលបានកើនឡើង បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩ (៧,៣%) និងត្រីមាសទី៣ ឆ្នាំ២០២០ (២៤,៩%)។ ធៀបនឹងពេលនេះក្នុងឆ្នាំមុន ការនាំចូលប្រេងសាំង បានកើនឡើង ៤,៨% សម្ភារៈសំណង់ ២៧,៩% និងទំនិញដែលមិនបញ្ជាក់ ៧,០%។ ធៀបនឹងត្រីមាសមុន ការនាំចូលប្រេងសាំងកើនឡើង ២,៤% សម្ភារៈសំណង់ ១០,១% និងទំនិញដែលមិនបញ្ជាក់ ២៩,៤%។ ផ្ទុយទៅវិញ ការនាំចូលប្រេងម៉ាស៊ូត ធ្លាក់ចុះ ៥,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និង ១៣,៨% ធៀបនឹងត្រីមាសមុន។

ការប្រៀបធៀបរវាងការនាំចេញ និងការនាំចូល បានបង្ហាញថា ជញ្ជីងពាណិជ្ជកម្មរបស់កម្ពុជានៅត្រីមាសទី៤ នេះ កំពុងមានឱនភាពម្ដងទៀត បន្ទាប់ពីជញ្ជីងពាណិជ្ជកម្ម បានលេចរូបរាងជាលើកដំបូងនៅក្នុងត្រីមាសមុន។ ជញ្ជីងពាណិជ្ជកម្មនៅត្រីមាសនេះ មានចំនួន -១.៧៣៦,៧លានដុល្លារ។

ប្រាក់ចំណូលសរុបនៅត្រីមាសទី៤ ឆ្នាំ២០២០ មានចំនួន ៥.៨៩១,៣លានដុល្លារ បានធ្លាក់ចុះ ១៥,០% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០១៩ ប៉ុន្តែនេះជាការកើនឡើងបាន ៤០,៦% បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០។ ការធ្លាក់ចុះប្រាក់ចំណូលសរុបពីមួយឆ្នាំមុន បណ្ដាលមកពីការធ្លាក់ចុះចំណូលចរន្ត (១៥,៣%)

---

អត្ថបទនេះ រៀបរៀងដោយលោក រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ នៅវិទ្យាស្ថាន CDRI។

ចំណូលពន្ធ (១០,២%) និងចំណូលមិនមែនពន្ធ (៥១,០%) ទោះជាមានកំណើនចំណូលមូលធនបាន ២២,៦% ក៏ដោយ។ ការធ្លាក់ចុះចំណូលពន្ធ គឺដោយសារការធ្លាក់ចុះពន្ធក្នុងស្រុក (៩,០%) និងពន្ធពាណិជ្ជកម្មអន្តរជាតិ (១៨,២%)។ ទោះជាមានកំណើនប្រាក់ចំណូលអចលនទ្រព្យ (៦៣,៨%) និងចំណូលមិនមែនពន្ធផ្សេងទៀត (១,៦%) ការធ្លាក់ចុះក្នុងការលក់ទំនិញនិងសេវាកម្ម ៦០,៦% បានបណ្ដាលឱ្យមានការធ្លាក់ចុះ ៥១,០% នៃចំណូលមិនមែនពន្ធដែរ។ ធៀបនឹងត្រីមាសមុន ចំណូលគ្រប់ប្រភេទបានរើបឡើងវិញ៖ ចំណូលចរន្ត ៤០,២% ចំណូលពន្ធ ៣៨,៨% ចំណូលមិនមែនពន្ធ ៦០,២% និងចំណូលមូលធន ៨៦,៩%។ ការកើនឡើងចំណូលពន្ធ គឺជាលទ្ធផលកំណើនពន្ធក្នុងស្រុក ៣៩,៨% និងពន្ធពាណិជ្ជកម្មអន្តរជាតិ ៣១,៧%។ ការរើបឡើងវិញប្រាក់ចំណូលមិនមែនពន្ធស្មើនឹង ៦០,២% ពីត្រីមាសមុន ដោយសារតែមានកំណើនចំណូលលើអចលនទ្រព្យបាន ២០,៦% ការលក់ទំនិញនិងសេវាកម្មបាន ៥៥,១% និងចំណូលមិនមែនពន្ធបាន ១១៣,៣%។

ការចំណាយសរុបនៅត្រីមាសទី៤ នេះ មានចំនួន ៧.៥០១,៩ លានដុល្លារ ដែលទាបជាង ២,៣% ធៀបនឹងត្រីមាសដូចគ្នាកាលពីឆ្នាំមុន (២០១៩) ប៉ុន្តែចំនួននេះកើនឡើង ៣៥,៣% បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០។ ធៀបនឹងពេលនេះក្នុងឆ្នាំមុន ចំណាយមូលធន ធ្លាក់ចុះ ៨,៩% បើទោះបីជាមានកំណើន ២,៤% នៃចំណាយចរន្ត ដែលជំរុញដោយកំណើនប្រាក់ឈ្នួល ១៥,១% ទោះជាប្រាក់ឧបត្ថម្ភនិងជំនួយសង្គម ធ្លាក់ចុះ ៨,៦% និងចំណាយចរន្តផ្សេងទៀត ធ្លាក់ចុះ ៦,៨% ក៏ដោយ។

ទោះជាចំណូលសរុបរើបឡើងវិញបាន ៤០,៦% ពីត្រីមាសមុនក៏ដោយ ក៏តុល្យភាពថវិកាជាតិសរុប នៅតែមានឱនភាព ១.៦១០,៥លានដុល្លារ។ ដើម្បីដោះស្រាយជាមួយនឹងឱនភាពនេះ រដ្ឋាភិបាលបានប្រើហិរញ្ញប្បទានបរទេសចំនួន ១.២៣៨,៣ លានដុល្លារ ខណៈហិរញ្ញប្បទានក្នុងស្រុកស្ថិតក្នុងកម្រិតអវិជ្ជមាន (-១៧,៥លានដុល្លារ)។ គួរកត់សម្គាល់ថា កម្រិតហិរញ្ញប្បទានបរទេសនៅត្រីមាសនេះស្មើនឹង ១០,៥% ទាបជាងត្រីមាសដូចគ្នាឆ្នាំមុន និង ១២,៥% ទាបជាងត្រីមាសទី៣ ឆ្នាំ២០២០។

សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ (CPI) ជាមធ្យមនៅត្រីមាសនេះ មាន ៣,៤% ត្រូវជា ០,៦% ឯកតាភាគរយ ខ្ពស់ជាង ត្រីមាសដូចគ្នាកាលពីឆ្នាំមុន និង ១,៤ ខ្ពស់ជាងត្រីមាសមុន។ សន្ទស្សន៍ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិអាល់កុល មានចំនួន ៥,៥% ដែលនេះជាការកើនឡើងបាន ១,០% ធៀបនឹងត្រីមាសដូចគ្នាកាលពីឆ្នាំមុន និង ៣,១% ធៀបនឹងត្រីមាសមុន។ សន្ទស្សន៍ថ្លៃដឹកជញ្ជូនមាន -៤,៩% ថយចុះ ០,៣% ធៀបនឹងត្រីមាសដូចគ្នាកាលពីឆ្នាំមុន និង ៣,៥% ធៀបនឹងត្រីមាសមុន។

ធៀបនឹងត្រីមាសមុន ប្រាក់រៀលបានឡើងថ្លៃ ០,៨% ធៀបនឹងដុល្លារអាមេរិក ពី ៤.០៩៤,៦រៀល ទៅ ៤.០៦៣,៨ រៀលក្នុងមួយដុល្លារ និង ១,១% ធៀបនឹងប្រាក់វៀតណាម ដល់ ១៧,៥ រៀលក្នុង ១០០ដុង ប៉ុន្តែវាធ្លាក់ចុះ ១,៥% ធៀបនឹងប្រាក់បាតថៃ។

តម្លៃមាសបានកើនឡើង ០,៨% ស្មើនឹង ២២៦,១ដុល្លារក្នុងមួយជី និងប្រេងសាំង ០,០៤% ដល់ ៣.០០៤,៩រៀលក្នុងមួយលីត្រ ខណៈតម្លៃប្រេងម៉ាស៊ូត ធ្លាក់ចុះ ២,៨% មក ២.៦៥៤,៩ រៀលក្នុងមួយលីត្រ។

## ចំណូលកម្មករខាងយរងគ្រោះជាមធ្យមប្រចាំថ្ងៃពិត

ផ្នែកនេះផ្ដល់នូវទិដ្ឋភាពសង្ខេបនៃ លទ្ធផលពីអង្កេតជាមួយកម្មករចំនួន ៤៨០នាក់ នៅខែកុម្ភៈឆ្នាំ២០២១។ ដោយសារជំងឺរាតត្បាតកូវីដ-១៩ អង្កេតជាមួយកម្មករនៅវាលស្រែ មិនអាចធ្វើបានទេ សម្រាប់របាយការណ៍ប្រចាំត្រីមាសនេះ។ គេអាចមើលឃើញចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីក្លូ អ្នករត់តុ អ្នករើសអេតចាយ អ្នករត់ម៉ូតូឌុប និងកម្មករសំណង់មានជំនាញ បានថយចុះ ចំណែកអ្នកលក់បន្លែតូចតាច អ្នករត់តុ កម្មករកាត់ដេរ និងកម្មករសំណង់គ្មានជំនាញ បានកើនឡើង។ កម្មករសំណង់គ្មានជំនាញ ទទួលបានប្រាក់ចំណូលប្រចាំថ្ងៃខ្ពស់បំផុត ហើយវាគឺជាត្រីមាសទី១ ចាប់តាំងពីរយៈពេលទទួលបានទិន្នន័យតាំងពីឆ្នាំ២០១៦ មក ដែលកម្មករប្រភេទនេះ ទទួលបានប្រាក់ចំណូលប្រចាំថ្ងៃ ខ្ពស់ជាងកម្មករសំណង់មានជំនាញដែលប្រាក់ចំណូលពួកគេ បានថយចុះ ១២,៧% បើធៀបនឹងត្រីមាសមុន។ ដោយមានកំណើនចំណូលប្រចាំថ្ងៃ ៤៤,៥% អ្នកលក់បន្លែតូចតាច ទទួលបានចំណេញខ្ពស់ជាងគេទី៣ គឺ ២១.៩៧៩រៀល បន្ទាប់ពីកម្មករសំណង់មានជំនាញ (២៣.៧១៧រៀល) និង កម្មករសំណង់គ្មានជំនាញ (២៣.៩៧៤រៀល)។ អ្នករើសអេតចាយ បានក្លាយជាកម្មករមានប្រាក់ចំណូលទាបបំផុត ដោយសារការធ្លាក់ចុះប្រាក់ចំណូលប្រចាំថ្ងៃ ៣៨,០% មកនៅត្រឹម ៩១៤៧រៀល។

ទាក់ទងនឹងចំណាយ អ្នករត់តុ/អ្នកបម្រើ មានភាគរយចំណាយច្រើនជាងគេ បើប្រៀបធៀបនឹងចំណូលប្រចាំខែ ដោយប្រើប្រាស់ចំណូលប្រចាំខែអស់ ៧០,៧% បន្ទាប់មក គឺអ្នករើសអេតចាយ អ្នកស៊ីក្លូ កម្មករសំណង់ជំនាញ កម្មករសំណង់គ្មានជំនាញ អ្នកលក់បន្លែតូចតាច កម្មករកាត់ដេរ និងអ្នកបើកបរម៉ូតូតាក់ស៊ី។ ជាមធ្យម កម្មករចំនួន ៣២០នាក់ មិនរាប់បញ្ចូល កម្មករកាត់ដេរ ភាគច្រើនបានប្រើប្រាស់ប្រាក់ចំណូលរបស់ពួកគេលើ ការចាយវាយសំខាន់ទៅលើម្ហូបអាហារ (៦៦,៣%) កន្លែងស្នាក់នៅ (១៨,៧%) ការដឹកជញ្ជូន (៤,៤%) សុខភាព (១,៥%) និងរបស់របរផ្សេងទៀត (៩,១%)។ ការចំណាយជាមធ្យមរបស់កម្មករកាត់ដេរ (n=១២០) ក៏ត្រូវបានបែងចែកជាចម្បងទៅលើអាហារ (៦៦,៦%) កន្លែងស្នាក់នៅ (២១,១%) ការដឹកជញ្ជូន (០,៤%) សុខភាព (១,១%) និងផ្សេងទៀត (១០,៨%)។ ធៀបចំណាយ នឹងចំណូល កម្មករសំណង់មានជំនាញ នៅសល់ប្រាក់ច្រើនជាងគេ សម្រាប់គ្រួសារ ទោះបីជាប្រាក់សន្សំពីការរកបានមានតែ ២៧,៤% នៃប្រាក់ចំណូលសរុបក៏ដោយ។ កម្មករសំណង់គ្មានជំនាញ សន្សំបានខ្ពស់ជាងគេទី២ សម្រាប់គ្រួសារ (២៨,៥% នៃប្រាក់ចំណូល) អ្នកលក់បន្លែ (៣៥,៨%) កម្មករកាត់ដេរ (៤៦,១%) អ្នកលីសែង (៥០,៤%) អ្នកបម្រើ/អ្នករត់តុ (២៩,៣%) អ្នករត់ម៉ូតូឌុប (៥៦,៧%) អ្នកជាក់ស៊ីក្លូ (៥៣,៧%) និងអ្នករើសអេតចាយ (យ៉ាងហោចណាស់ ៥២,០% នៃប្រាក់ចំណូល)។

## តារាង១៖ គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០១៥-២០

| | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 169.8 | 117.1 | 62.9 | 214.9 | 17.2 | 48.2 | 1.9 | 27.5 | 0.0 | 35.8 | 31.7 | 0.0 |
| ឧស្សាហកម្ម | 1014.7 | 1436.4 | 982.2 | 1186.2 | 292.9 | 113.7 | 302.0 | 919.9 | 234.0 | 737.0 | 1941.8 | 1654.2 |
| *. សម្លៀកបំពាក់* | 225.2 | 380.7 | 211.1 | 187.3 | 73.9 | 34.4 | 47.3 | 74.1 | 106.0 | 55.5 | 29.7 | 56.4 |
| សេវាកម្ម | 2734.4 | 1664.3 | 3858.6 | 4351.8 | 1625.6 | 2518.2 | 849.7 | 1440.4 | 682.1 | 481.2 | 1722.4 | 9.6 |
| *. សណ្ឋាគារ និងទេសចរណ៍* | 98.6 | 1366.9 | 2759.6 | 1584.0 | 1618.8 | 2518.2 | 808.7 | 1703.8 | 133.0 | 202.4 | 3515.1 | 0.0 |
| សរុប | 3918.9 | 3217.7 | 4903.7 | 5752.9 | 1935.6 | 2680.1 | 1153.5 | 2387.8 | 916.1 | 1254.1 | 3696.0 | 1663.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 4.9 | 38.5 | -57.0 | 107.0 | -61.6 | 36.9 | -85.3 | -55.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 147.4 | -17.9 | 52.4 | 17.3 | 312.5 | 12.6 | 8.9 | 29.4 | -52.7 | -53.2 | -84.0 | -30.3 |

Note: Including expansion project approvals. Source: Cambodian Investment Board

## តារាង២៖ តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ ផ្ទះ និងផ្ទះល្វែង | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 227.3 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1,010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | - |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣៖ ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០១៥-២០

| | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| ចិន | 694.7 | 830.0 | 1,210.8 | 2,024.4 | 683.4 | 609.1 | 572.5 | 496.9 | 259.7 | 15.9 | 27.2 | 26.8 |
| វៀតណាម | 987.8 | 959.7 | 835.4 | 800.1 | 186.9 | 214.8 | 235.7 | 271.5 | 179.5 | 0.2 | 1.1 | 1.4 |
| កូរ៉េខាងត្បូង | 395.3 | 357.2 | 345.0 | 301.8 | 95.7 | 43.6 | 47.4 | 68.1 | 41.7 | 1.0 | 1.8 | 1.5 |
| ថៃ | 349.9 | 398.1 | 394.9 | 382.3 | 97.9 | 76.3 | 113.9 | 178.4 | 152.7 | 8.4 | 28.4 | 21.4 |
| សហរដ្ឋអាមេរិក | 217.5 | 238.7 | 256.5 | 250.8 | 79.0 | 53.2 | 45.5 | 71.2 | 42.7 | 0.3 | 1.4 | 1.3 |
| ជប៉ុន | 193.3 | 191.6 | 203.4 | 210.5 | 60.2 | 40.4 | 48.9 | 58.2 | 39.8 | 0.2 | 0.7 | 0.6 |
| បារាំង | 145.7 | 150.3 | 166.4 | 170.8 | 59.4 | 27.3 | 32.9 | 44.5 | 41.8 | 0.1 | 0.7 | 0.6 |
| ចក្រភពអង់គ្លេស | 154.3 | 159.5 | 171.2 | 162.4 | 59.4 | 29.7 | 28.5 | 45.6 | 44.2 | 0.1 | 0.3 | 0.2 |
| ម៉ាឡេស៊ី | 149.4 | 152.8 | 179.3 | 201.1 | 48.7 | 43.2 | 46.5 | 64.6 | 24.9 | 0.1 | 0.3 | 0.4 |
| តាមផ្លូវអាកាស | 2476.0 | 2778.0 | 3312.7 | 6405.6 | 1299.1 | 1054.8 | 1039.9 | 1010.2 | 663.6 | 26.3 | 36.3 | 37.9 |
| តាមផ្លូវគោក និងទឹក | 2299.2 | 2331.4 | 2289.4 | 3242.2 | 578.7 | 405.8 | 436.0 | 786.1 | 491.6 | 8.4 | 28.5 | 21.4 |
| សរុប | 4775.2 | 4980.4 | 5602.2 | 9647.7 | 1877.9 | 1460.6 | 1475.8 | 1796.3 | 1155.2 | 34.7 | 64.9 | 58.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 2.9 | -22.2 | 1.0 | 21.7 | -35.7 | -97.0 | 87.0 | -9.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 6.1 | 4.3 | 12.5 | 72.2 | 9.7 | 13.2 | 7.4 | -1.6 | -38.5 | -97.6 | -95.6 | -96.7 |

Source: Ministry of Tourism

## តារាង៤៖ ការនាំចេញ និងនាំចូល ឆ្នាំ២០១៥-២០ *

| | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 9256.4 | 10043.3 | 10772.9 | 12783.8 | 3222.7 | 3379.0 | 4263.9 | 3524.9 | 3550.1 | 4251.5 | 5562.2 | 3970.9 |
| សម្លៀកបំពាក់ | 6827.0 | 7308.0 | 8020.3 | 9506.0 | 2463.4 | 2526.3 | 3143.8 | 2530.9 | 2647.2 | 1983.8 | 2705.4 | 2579.1 |
| - *សហរដ្ឋអាមេរិក* | 2009.4 | 1831.5 | 1923.8 | 2483.2 | 739.8 | 802.9 | 1006.5 | 848.0 | 945.9 | 694.3 | 1038.6 | 975.9 |
| - *សហភាពអឺរ៉ុប* | 2903.9 | 2928.7 | 2782.2 | 3155.3 | 719.2 | 801.1 | 965.4 | 716.2 | 706.3 | 579.9 | 661.2 | 703.0 |
| - *អាស៊ាន* | 103.4 | 98.4 | 106.9 | 135.3 | 38.1 | 41.3 | 48.2 | 53.1 | 54.6 | 54.6 | 48.8 | 53.5 |
| - *ជប៉ុន* | 524.2 | 655.5 | 701.2 | 890.8 | 262.9 | 175.8 | 291.2 | 236.8 | 262.9 | 156.7 | 230.8 | 219.8 |
| - *ចក្រភពអង់គ្លេស* | - | 439.8 | 904.0 | 1007.0 | 211.5 | 197.7 | 272.9 | 200.3 | 190.2 | 136.6 | 223.4 | 168.7 |
| - *ប្រទេសផ្សេងៗ* | 1286.3 | 1354.2 | 1602.2 | 1834.3 | 491.7 | 507.5 | 559.7 | 476.4 | 487.3 | 361.7 | 502.8 | 458.3 |
| គ្រឿងអេឡិចត្រូនិក | - | - | 380.0 | 328.7 | 71.9 | 123.8 | 142.3 | 116.3 | 113.0 | 111.0 | 183.2 | 226.6 |
| គ្រឿងយានយន្ត | - | - | 11.6 | 94.4 | 20.4 | 18.2 | 22.7 | 24.1 | 26.0 | 43.0 | 35.4 | 42.7 |
| កសិកម្ម | 548.8 | 534.1 | 706.4 | 850.9 | 210.4 | 177.7 | 211.0 | 288.1 | 262.9 | 304.5 | 277.4 | 440.2 |
| - *កៅស៊ូ* | 165.4 | 165.3 | 273.5 | 217.6 | 43.8 | 42.2 | 60.0 | 73.3 | 30.8 | 40.0 | 83.1 | 119.4 |
| - *ឈើ* | 46.3 | 47.2 | 100.5 | 142.3 | 22.2 | 35.2 | 42.4 | 47.5 | 44.0 | 93.8 | 86.0 | 130.8 |
| - *ត្រី* | 0.5 | 0.6 | 0.6 | 1.3 | 0.1 | 0.1 | 0.1 | 0.1 | 0.1 | 0.1 | 0.1 | 0.1 |
| - *អង្ករ* | 315.3 | 300.8 | 255.1 | 413.6 | 122.4 | 72.2 | 84.5 | 140.2 | 145.9 | 105.5 | 62.6 | 142.6 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 21.3 | 20.2 | 76.7 | 76.2 | 21.9 | 28.1 | 24.1 | 26.9 | 42.2 | 65.1 | 45.6 | 47.3 |
| ផ្សេងៗ | 1880.2 | 2201.2 | 1654.7 | 2003.8 | 456.6 | 532.9 | 744.0 | 565.6 | 501.0 | 1809.2 | 2360.7 | 686.2 |
| ការនាំចូលសរុប | 11494.5 | 15013.4 | 16815.4 | 16904.7 | 4437.7 | 5328.6 | 5091.4 | 5324.3 | 5250.9 | 4361.5 | 4571.6 | 5711.6 |
| សាំង | 377.3 | 384.8 | 256.7 | 320.5 | 121.1 | 117.1 | 118.6 | 121.9 | 131.4 | 122.6 | 124.8 | 127.8 |
| ម៉ាស៊ូត | 607.8 | 709.1 | 472.9 | 594.1 | 228.2 | 250.2 | 166.4 | 248.9 | 248.1 | 265.1 | 274.2 | 236.4 |
| សម្ភារសំណង់ | 164.4 | 253.2 | 304.3 | 564.5 | 170.8 | 231.4 | 271.2 | 224.4 | 177.0 | 213.5 | 260.8 | 287.1 |
| ផ្សេងៗ | 10345.1 | 13666.3 | 15781.6 | 15425.7 | 3917.7 | 4729.9 | 4535.2 | 4729.1 | 4694.4 | 3760.4 | 3911.9 | 5060.2 |
| ជញ្ជីងពាណិជ្ជកម្ម | -2238.1 | -4970.0 | -5974.1 | -4120.9 | -1215.0 | -1990.6 | -827.5 | -1799.4 | -1700.9 | -110.1 | 990.5 | -1736.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | 7.0 | 2.6 | 24.4 | -19.5 | 4.6 | -25.1 | 36.4 | -4.7 |
| ការនាំចេញសរុប | - | - | - | - | 2.8 | 7.8 | 26.2 | -17.3 | 0.7 | 19.8 | 30.8 | -28.6 |
| ការនាំចូលសរុប | - | - | - | - | 6.0 | 27.2 | -4.5 | 4.6 | -1.4 | -16.9 | 4.8 | 24.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 14.5 | 7.0 | 9.7 | 18.5 | 17.7 | 12.8 | 9.5 | 9.9 | 7.5 | -21.5 | -13.9 | 1.9 |
| ការនាំចេញសរុប | 14.2 | 8.5 | 7.9 | 17.9 | 13.7 | 12.6 | 11.8 | 12.4 | 10.2 | 25.8 | 30.4 | 12.7 |
| ការនាំចូលសរុប | 11.7 | 30.6 | 12.0 | 0.5 | 4.6 | 18.5 | 28.0 | 27.1 | 18.3 | -18.1 | -10.2 | 7.3 |

Note: Import data include tax-exempt imports. Sources: Department of Trade Preference Systems; MOC and Customs and Excise Department; MEF (website)

## តារាង៥៖ ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០១៥-២០ (ប៊ីលានរៀល)

| | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 11879.9 | 14201.5 | 16582.0 | 19743.1 | 5097.5 | 6357.1 | 6364.5 | 6930.3 | 5544.2 | 5554.9 | 4189.8 | 5891.3 |
| ចំណូលចរន្ត | 11759.0 | 14088.7 | 16481.4 | 19549.0 | 5066.8 | 6322.2 | 6309.2 | 6869.7 | 5524.0 | 5504.1 | 4150.0 | 5817.0 |
| ចំណូលពន្ធ | 10502.4 | 12196.5 | 14314.3 | 17019.2 | 4524.3 | 5663.5 | 5415.1 | 6009.8 | 4697.1 | 5236.7 | 3886.8 | 5395.3 |
| ពន្ធក្នុងស្រុក | 8591.7 | 10185.8 | 12338.7 | 14648.3 | 3904.9 | 4944.9 | 4634.1 | 5215.9 | 4076.5 | 4787.8 | 3393.8 | 4745.9 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1910.7 | 2010.7 | 1875.6 | 2370.9 | 619.4 | 718.6 | 781.0 | 793.9 | 620.6 | 448.9 | 493.0 | 649.4 |
| ចំណូលមិនមែនពន្ធ | 1256.6 | 1892.2 | 2167.2 | 2520.9 | 542.5 | 658.7 | 894.1 | 859.9 | 826.9 | 267.4 | 263.2 | 421.7 |
| ចំណូលលើទ្រព្យសម្បត្តិ | 77.3 | 116.0 | 127.2 | 197.3 | 177.4 | 34.0 | 30.2 | 22.9 | 289.6 | 36.8 | 31.1 | 37.5 |
| លក់ទំនិញ និងសេវា | 1047.1 | 1248.3 | 1517.0 | 2075.6 | 330.7 | 531.2 | 798.5 | 750.0 | 500.9 | 211.6 | 190.7 | 295.7 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 132.2 | 528.0 | 523.1 | 253.9 | 34.5 | 93.5 | 65.5 | 87.1 | 36.4 | 47.5 | 41.5 | 88.5 |
| ចំណូលជាមូលធន | 121.0 | 113.4 | 100.5 | 194.1 | 30.7 | 35.0 | 55.4 | 60.7 | 20.2 | 50.8 | 39.8 | 74.4 |
| ចំណាយសរុប | 13849.5 | 13775.4 | 17251.0 | 19027.1 | 4150.4 | 4997.6 | 5386.5 | 7676.8 | 5301.7 | 6342.8 | 5546.4 | 7501.9 |
| ចំណាយជាមូលធន | 5290.3 | 3785.3 | 5207.2 | 5730.2 | 1025.0 | 1392.7 | 1358.6 | 3195.4 | 1259.3 | 2289.2 | 1757.1 | 2912.1 |
| ចំណាយចរន្ត | 8544.6 | 9990.1 | 12043.7 | 13297.0 | 3125.4 | 3604.9 | 4027.9 | 4481.3 | 4042.5 | 4053.5 | 3846.7 | 4589.8 |
| បៀវត្សរ៍ | 4271.9 | 5381.7 | 6647.4 | 7558.4 | 1820.2 | 1911.1 | 2102.0 | 1883.3 | 2058.0 | 1934.4 | 2132.8 | 2167.6 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 1742.9 | 1774.9 | 2314.8 | 2505.4 | 729.2 | 1061.9 | 855.5 | 1620.3 | 1288.2 | 1435.6 | 701.5 | 1481.5 |
| ចំណាយចរន្តផ្សេងទៀត | 2529.8 | 2833.5 | 5394.3 | 5738.6 | 1305.2 | 1693.8 | 1925.8 | 2598.1 | 1984.4 | 2119.2 | 1713.9 | 2422.2 |
| សមតុល្យជាទូទៅ | -1969.6 | 426.1 | -669.1 | -205.4 | 947.1 | 1,359.6 | 978.0 | -746.4 | 242.4 | -787.9 | -1356.5 | -1610.5 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 3729.4 | 1878.9 | 3358.1 | 716.1 | 652.8 | 895.5 | 608.8 | 1383.3 | 369.5 | 1180.5 | 1415.7 | 1238.3 |
| ហិរញ្ញប្បទានក្នុងស្រុក | -2034.9 | -1858.7 | -2454.1 | 2513.5 | -44.4 | -7.6 | 11.9 | -18.0 | 3.2 | 18.7 | 113.1 | -17.5 |

Source: MEF website

## តារាង៦៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០១៥-២០

| | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 1.2 | 3.1 | 2.9 | 2.5 | 1.9 | 1.8 | 2.0 | 2.0 | 3.0 | 2.5 | 2.8 | 3.4 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 4.0 | 5.6 | 3.4 | 2.5 | 2.1 | 1.6 | 2.2 | 2.4 | 3.7 | 4.9 | 4.5 | 5.5 |
| - ដឹកជញ្ជូន | -9.2 | -6.9 | 4.1 | 2.9 | -3.8 | -1.5 | -2.5 | -1.4 | 2.6 | -10.8 | -4.6 | -4.9 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4060.4 | 4053.7 | 4047.5 | 4045.0 | 4006.6 | 4052.1 | 4086.8 | 4063.7 | 4064.1 | 4087.0 | 4094.6 | 4063.8 |
| រៀលក្នុង ១ បាតថៃ | 119.4 | 115.5 | 120.0 | 125.9 | 127.4 | 128.9 | 133.7 | 134.9 | 130.7 | 127.5 | 131.0 | 133.0 |
| រៀលក្នុង ១០០ ដុងវៀតណាម | 18.7 | 18.2 | 17.9 | 17.7 | 17.4 | 17.5 | 17.7 | 17.6 | 17.6 | 17.7 | 17.7 | 17.5 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 140.6 | 151.2 | 151.5 | 152.8 | 156.6 | 157.1 | 175.7 | 178.1 | 188.3 | 185.5 | 224.2 | 226.1 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3771.3 | 3004.0 | 3385.8 | 3808.7 | 3413.9 | 3595.4 | 3499.7 | 3499.5 | 3343.5 | 2393.0 | 2730.6 | 2654.9 |
| ថ្លៃសាំង (រៀល/លីត្រ) | 3951.7 | 3336.8 | 3716.0 | 3982.5 | 3405.7 | 3770.2 | 3629.3 | 3685.9 | 3538.8 | 2483.8 | 3003.7 | 3004.9 |

Sources: NIS; NBC; CDRI

## តារាង៧៖ ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០១៣-២០ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 26665.5 | 31814.5 | 42575.3 | 55214.3 | 58148.8 | 55238.0 | 58667.0 | 60182.9 | 57001.8 | 63515.6 | 68060.7 | 67602.5 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 22157.6 | 25802.3 | 28743.5 | 33228.9 | 33997.2 | 55274.0 | 34814.3 | 34856.1 | 62221.0 | 60598.8 | 64552.9 | 68040.1 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -6428.8 | -8148.5 | -11066.5 | -14803.7 | -17381.0 | -19828.0 | -21574.8 | -23884.4 | -24650.6 | -24152.1 | -24395.1 | -24994.7 |
| ឥណទានដល់វិស័យឯកជន | 46071.0 | 56458.8 | 66922.6 | 82419.3 | 86575.2 | 111686.0 | 119358.9 | 125629.4 | 131815.3 | 132849.9 | 139899.7 | 147822.1 |
| រូបិយវត្ថុទូទៅ | 48823.1 | 57616.6 | 71318.9 | 88443.2 | 92146.0 | 110512.0 | 116766.5 | 118436.4 | 119222.8 | 124114.4 | 132613.6 | 135642.6 |
| រូបិយវត្ថុ | 6741.4 | 7273.0 | 9428.4 | 10226.8 | 10782.0 | 9883.0 | 11933.4 | 11906.3 | 12880.5 | 12650.4 | - | - |
| រូបិយវត្ថុផ្សេងៗ | 42081.7 | 50343.8 | 61890.4 | 78216.4 | 81364.0 | 95196.0 | 98378.3 | 99650.6 | 99700.8 | 103956.6 | - | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ | 14.7 | 18.0 | 23.8 | 24.0 | 24.0 | 22.6 | 21.3 | 20.4 | 29.4 | 12.3 | 13.6 | - |
| រូបិយវត្ថុ | 6.9 | 7.9 | 29.6 | 8.5 | 8.5 | 12.6 | 18.0 | 32.7 | 19.5 | 28.0 | - | - |
| រូបិយវត្ថុផ្សេងៗ | 16.1 | 19.6 | 22.9 | 26.4 | 26.4 | 24.1 | 21.7 | 18.8 | 22.5 | 9.2 | - | - |

Source: National Bank of Cambodia

## តារាង៨៖ ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយ ធៀបនឹងឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2016 | 2017 | 2018 | 2019 | 2020 | | | | 2021 | 2020 | | 2021 |
| | | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | សីហា | វិច្ឆិកា | កុម្ភៈ |
| អ្នករត់ស៊ីក្លូ | 11516 | 10793 | 10774 | 11373 | 10997 | 9081 | 10779 | 10775 | 10469 | -3.0 | -10.6 | -4.8 |
| អ្នកលីសែង | 14318 | 14942 | 15345 | 17142 | 18246 | 17856 | 15346 | 19493 | 16126 | -7.3 | 3.7 | -11.6 |
| អ្នកលក់បន្លែតូចតាច | 17177 | 17015 | 20125 | 19558 | 15207 | 20181 | 19479 | 23206 | 21979 | 1.5 | 24.4 | 44.5 |
| អ្នករើសអេតចាយ | 10299 | 11591 | 12613 | 12962 | 14759 | 8322 | 10742 | 11198 | 9147 | -18.1 | -14.5 | -38.0 |
| អ្នករត់តុភោជនីយដ្ឋាន* | 7989 | 8093 | 8149 | 8484 | 8706 | 8420 | 8997 | 8912 | 11155 | 5.1 | 2.2 | 28.1 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 8088 | 8055 | 8668 | 8669 | 9154 | 8812 | 8712 | 8924 | - | -5.1 | -4.8 | - |
| កម្មកររោងចក្រកាត់ដេរ | 13688 | 14093 | 15242 | 15973 | 16483 | 13271 | 14211 | 14391 | 16552 | -11.6 | -13.2 | 0.4 |
| អ្នករត់ម៉ូតូឌុប | 11516 | 10793 | 10774 | 11373 | 17748 | 9081 | 15210 | 14427 | 17424 | 7.0 | -3.2 | -1.8 |
| កម្មករសំណង់គ្មានជំនាញ | 14509 | 14231 | 14815 | 14733 | 22916 | 19741 | 17870 | 14947 | 23974 | -2.5 | -20.6 | 4.6 |
| កម្មករសំណង់មានជំនាញ | 17365 | 17341 | 17573 | 18736 | 27164 | 26778 | 31298 | 22069 | 23717 | 24.0 | -18.9 | -12.7 |

Notes: * Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, ricefield workers, garment workers, motorcycle taxi drivers and construction workers began in February 2000. November 2015 data are not available. **Not available.